ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
**Ministry of Commerce**
No. ១៤០ MOC / M 2003

# ប្រកាស

## ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ នាយកដ្ឋានស្ថិតិ និងពត៌មាន

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខនស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យ លេខ ៩៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យ លេខ ១២៦ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ២០០២ ស្តីពីការបង្កើតនាយកដ្ឋានស្ថិតិ និងពត៌មានចំណុះអគ្គនាយកដ្ឋានបច្ចេកទេស នៃក្រសួងពាណិជ្ជកម្ម
- តាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សំរេច

**ប្រការ១** :

នាយកដ្ឋានស្ថិតិ និងពត៌មានស្ថិតនៅក្រោមការគ្រប់គ្រង និងដឹកនាំផ្ទាល់របស់អគ្គនាយកដ្ឋានបច្ចេកទេស មានតួនាទី និងភារកិច្ចដូចតទៅ ៖-

- ស្រាវជ្រាវ និងធ្វើស្ថិតិពាណិជ្ជកម្ម
- ធ្វើសហប្រតិបត្តិការលើវិស័យស្ថិតិ ពាណិជ្ជកម្ម ជាមួយបណ្តាប្រទេសក្នុងតំបន់ និងពិភពលោក
- សិក្សា និងសហការជាមួយអង្គភាពពាក់ព័ន្ធ រៀបចំ អង្កេត ប្រមូល ចងក្រង និងវិភាគពត៌មានស្ថិតិពាណិជ្ជកម្ម
- ចងក្រង និង ណែនាំអនុវត្តដោយឯកភាព តាមចំណាត់ថ្នាក់ពត៌មានស្ថិតិពាណិជ្ជកម្ម និងបណ្តាតារាងគំរូ
- ផ្សព្វផ្សាយទិន្នន័យស្ថិតិពាណិជ្ជកម្ម ស្តីពីស្ថានភាពនៃការវិវត្តន៍ក្នុងផ្នែកពាណិជ្ជកម្មក្នុង និងក្រៅប្រទេស
- ស្រាវជ្រាវ វិភាគ ផ្សព្វផ្សាយការប្រែប្រួលថ្លៃទំនិញចរាចរក្នុងប្រទេស និងត្រួតពិនិត្យតាមដានទិន្នាការសន្ទស្សន៍ថ្លៃរបស់បណ្តាប្រទេសនានា
- សិក្សា ស្រាវជ្រាវ ប្រមូល និងវិភាគពត៌មានតាមលំដាប់ដើម្បីបង្កើតតារាង នៃការប្រែប្រួលថ្លៃ និងការ

STATISTIC

ប្រែប្រួលគុណភាព
- ប្រមូលយកពត៌មានអំពីថ្លៃទំនិញប្រើប្រាស់និងសេវាកម្មតាមការកំណត់ និងចងក្រងការប្រែប្រួលថ្លៃទំនិញប្រើប្រាស់និង សេវាប្រចាំខែ ត្រីមាស ៩ខែ និងប្រចាំឆ្នាំ
- ធ្វើគំរោងបណ្តុះបណ្តាលសមត្ថភាពមន្ត្រីជំនាញផ្នែកស្ថិតិពាណិជ្ជកម្ម និងពត៌មានពាណិជ្ជកម្មពីថ្នាក់កណ្តាលរហូតដល់មូលដ្ឋានតាមវិវឌ្ឍការការងារ ។
- ទទួលបន្ទុកជា មជ្ឈមណ្ឌលពត៌មានពាណិជ្ជកម្ម របស់ក្រសួង
- គ្រប់គ្រង និង អភិវឌ្ឍន៍ពត៌មាន ប្រពន្ធ័ទិន្នន័យសេដ្ឋកិច្ចពាណិជ្ជកម្ម
- គ្រប់គ្រងនិង អភិវឌ្ឍន៍បច្ចេកទេសពត៌មានវិទ្យា ។

**ប្រការ២ :**

បង្កើតការិយាល័យចំនួន ៤ ចំណុះអោយកដ្ឋានស្ថិតិ និង ពត៌មាន :
- ការិយាល័យសំរបសំរួល
- ការិយាល័យសរុបស្ថិតិពត៌មានពាណិជ្ជកម្ម
- ការិយាល័យបច្ចេកទេសពត៌មានវិទ្យា
- ការិយាល័យផ្សព្វផ្សាយព័ត៌មានពាណិជ្ជកម្ម

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ ។ ការិយាល័យនីមួយៗធ្វើអន្តរកម្មដើម្បីផលប្រយោជន៍របស់វិស័យស្ថិតិ និងពត៌មានពាណិជ្ជកម្ម ។

**ប្រការ៣ :**

ការិយាល័យសំរបសំរួល ទទួលបន្ទុក :
- គ្រប់គ្រង និងចរាចរលិខិតរដ្ឋបាលផ្សេងៗរបស់នាយកដ្ឋានដោយធានាប្រសិទ្ធិភាព និងសុវត្ថិភាពឯកសារ
- សំរបសំរួលការងាររបស់នាយកដ្ឋានជាមួយការិយាល័យចំណុះ
- គ្រប់គ្រងអចលនទ្រព្យ និងចលនទ្រព្យក្នុងនាយកដ្ឋាន
- ស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកទេសពត៌មានវិទ្យា
- ធ្វើគំរោងបណ្តុះបណ្តាលសមត្ថភាពមន្ត្រីជំនាញស្ថិតិពាណិជ្ជកម្ម និង ពត៌មានពាណិជ្ជកម្ម
- គ្រប់គ្រងសំណុំឯកសារមន្ត្រីក្នុងនាយកដ្ឋាន ។

**ប្រការ៤ :**

ការិយាល័យសរុបស្ថិតិពត៌មានពាណិជ្ជកម្ម ទទួលបន្ទុក :
- ធ្វើរបាយការណ៍បូកសរុបការងារជូនថ្នាក់ដឹកនាំ
- រៀបចំបង្កើតគំរូតារាងលំអិតផ្សេងៗដើម្បីជាមូលដ្ឋានឱ្យនាយកដ្ឋាននិងមន្ទីរពាណិជ្ជកម្មខេត្តក្រុងរាយការណ៍
- វិភាគ ស្ថិតិពត៌មានពាណិជ្ជកម្ម និងវិភាគពីការប្រែប្រួលក្នុងវិស័យពាណិជ្ជកម្ម នាំចេញ នាំចូល អាជីវកម្ម សេវាកម្ម ។
- ធ្វើសហការវិស័យស្ថិតិពាណិជ្ជកម្មជាមួយបណ្តាប្រទេសក្នុងតំបន់ និងពិភពលោក
- ធ្វើស្ថិតិថ្លៃទំនិញ សំខាន់ៗ ដែលចរាចរលើទីផ្សារក្នុងប្រទេស និងក្រៅប្រទេស និងធ្វើសន្ទស្សន៍ថ្លៃទំនិញទាំងនោះ ។

**ប្រការ៥ :**

ការិយាល័យបច្ចេកទេសពត៌មានវិទ្យា ទទួលបន្ទុក :
- រៀបចំគេហទំព័រ (Home page) និងផ្សព្វផ្សាយលើ Website ពីទិន្នន័យស្ថិតិពាណិជ្ជកម្ម

- ផ្សព្វផ្សាយច្បាប់ទាក់ទងដល់ពាណិជ្ជកម្ម និងច្បាប់របស់អង្គការពាណិជ្ជកម្មពិភពលោកដល់ពាណិជ្ជករ និងក្រុមហ៊ុនក្នុងស្រុក
- ទទួលផ្សាយពាណិជ្ជកម្មតាម Website

**ប្រការ៦:**

ការិយាល័យផ្សព្វផ្សាយពត៌មានពាណិជ្ជកម្ម ទទួលបន្ទុក :

- រៀបចំស្ថិតិប្រចាំថ្ងៃ ប្រចាំអាទិត្យ ខែ ត្រីមាស ឆមាស ៩ខែ និងឆ្នាំជូនក្រសួង
- ផ្តល់ពត៌មានសំរាប់នាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេសចុះផ្សាយក្នុងព្រឹត្តិប័ត្ររបស់ក្រសួងពាណិជ្ជកម្ម
- ធ្វើសេវាផ្តល់ពត៌មានទាក់ទងស្ថិតិពាណិជ្ជកម្មកម្ពុជានិងពិភពលោកដោយយកកំរៃរដ្ឋបាលមួយសមស្រប ។

**ប្រការ៧ :**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៨ :**

អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានស្ថិតិនិងពត៌មាន ប្រធាននាយកដ្ឋានបុគ្គលិក និងប្រធាននាយកដ្ឋានពាក់ពន្ធ័ ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ៦ ឆ្នាំ២០០៣

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

កន្លែងទទួល :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់នាយកដ្ឋាន មន្ទីរពាណិជ្ជកម្មខេត្ត-ក្រុង
- ដូចប្រការ៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ